**សុន្ទរកថាស្វាគមន៍**

**របស់បណ្ឌិត ជា ទុធណា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ក្នុងសិក្ខាសាលាស្តីពី

“**គោលការណ៍ណែនាំសវនកម្មសមិទ្ធកម្ម សវនកម្មលើគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និង សវនកម្មបច្ចេកវិទ្យាព័ត៌មាន**”

រាជធានីភ្នំពេញ ថ្ងៃទី២៤-២៨ ខែសីហា ឆ្នាំ២០២០

- សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាសវនករផ្ទៃក្នុងទាំងអស់កំពុងអនឡាញ និងតាមការបញ្ចាំងប្រូចិកទ័រ
- សូមគោរពលោក សុខ កែវរស្មី និងកញ្ញា ចាន់ សារ៉ាត់ ទីប្រឹក្សាក្នុងស្រុក

**១-** ថ្ងៃនេះ ពិតជាថ្ងៃដ៏វិសេសថ្មីមួយទៀត ដែលយើងទាំងអស់គ្នា ជាសវនករផ្ទៃក្នុងនៃក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈរបស់រាជរដ្ឋាភិបាល បានមកចូលរួមក្នុងសិក្ខាសាលា ស្តីពី “**គោលការណ៍ណែនាំសវនកម្មសមិទ្ធកម្ម សវនកម្មលើគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន**” ដែលរៀបចំដោយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធអនឡាញ ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជម្ងឺកូវីត-១៩ និងដែលក្លាយជា “**ទម្លាប់ធម្មតាថ្មី** New Nomal Order”រួចទៅហើយសម្រាប់យើងទាំងអស់គ្នា។ គោលការណ៍ណែនាំសវនកម្មទាំងបីនេះ គឺជាសមិទ្ធកម្មថ្មីស្រឡាងបន្ថែម នៅក្នុងប្រវត្តិសាស្ត្រនៃការពង្រឹងសមត្ថភាពស្ថាប័នសវនកម្មផ្ទៃក្នុងរបស់រាជរដ្ឋាភិបាលកម្ពុជា និងក៏ជាបង្គោលចរថ្មីមួយទៀត នៅក្នុងវិថីនៃកំណែទម្រង់វិស័យសាធារណៈដ៏ធំទូលាយនិងវែងឆ្ងាយ។ តាងនាមឱ្យក្រុមការងាររៀបចំអង្គសិក្ខាសាលានេះ ខ្ញុំសូមអរគុណចំពោះការចូលតាមរួមអនឡាញរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាសវនករផ្ទៃក្នុងចំនួន១១៩ រូបពីក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈរបស់រាជរដ្ឋាភិបាលចំនួន៤៩ ដោយពុំរាប់បញ្ចូលនូវសវនករដទៃទៀត ដែលកំពុងចូលរួមនៅតាមអង្គភាពរៀងៗខ្លួនតាមការបញ្ចាំងប្រូចិកទ័រ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

**២-** ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា បានឆ្លងដល់ដំណាក់កាលមួយដែលទាមទារឱ្យមានសេវាសវនកម្មសមិទ្ធកម្ម។ ដំណាក់កាលទី១ “**ការបង្កើនភាពជឿទុកចិត្តលើថវិកា**” (ការពង្រឹងការគ្រប់គ្រងចំណូល និងសាច់ប្រាក់ ដើម្បីដោះស្រាយបំណុល និងកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ) និង

ដំណាក់កាលទី២ “**ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ**” (ពង្រឹងការកត់ត្រា និងរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ តាមរយៈការកសាងចំណាត់ថ្នាក់ថវិកាថ្មី ប្លង់គណនេយ្យថ្មី ថវិកាកម្មវិធី អង្គភាពថវិកា នីតិវិធីអនុវត្តថវិកាថ្មី និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុ (FMIS)) ត្រូវបានបញ្ចប់ និងកំពុងត្រៀមលក្ខណៈឆ្លងដំណាក់កាលទី៣ “**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**” (ប្រព័ន្ធថវិកាផ្អែកលើលទ្ធផលឬធាតុចេញ និងវិមជ្ឈការ តាមរយៈការពង្រឹង និងពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី និងអង្គភាពថវិកា រួមទាំងការងារគាំទ្រដទៃទៀត)។ រីឯដំណាក់កាលទី៤ “**គណនេយ្យភាពសមិទ្ធកម្ម**” គ្រោងនឹងអនុវត្តចាប់ពីឆ្នាំ២០២១ ដល់២០២៥។ ក្នុងដំណាក់កាលនេះ ប្រព័ន្ធថវិកានឹងឈានដល់កម្រិតវិមជ្ឈការខ្ពស់ទាំងក្នុងទម្រង់ និងខ្លឹមសារ ទាំងនៅថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ ដែលមានអង្គភាពថវិកាជាតួអង្គសកម្ម ទទួលប្រតិភូកម្មសិទ្ធិអំណាចពេញលេញក្នុងការចាត់ចែងគ្រប់គ្រង និងទទួលខុសត្រូវលើគណនេយ្យភាពសមិទ្ធកម្មរបស់ខ្លួន។ ការចាត់ចែង និងគ្រប់គ្រងថវិកាប្រចាំឆ្នាំរបស់អង្គភាពថវិកា ត្រូវប្រព្រឹត្តទៅតាមផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំ ដែលបានរៀបចំស្របតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពជាមួយសូចនាករលទ្ធផលច្បាស់លាស់ ដើម្បីគាំទ្រដល់ការឈានទៅសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័នរបស់ខ្លួន។ ការសម្រេចបាននូវសូចនាករលទ្ធផលតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពនិងសកម្មភាពនីមួយៗ ប្រហែលជាពុំទាន់អាចចាត់ទុកជាការវាយតម្លៃស្ថាពរថា អង្គភាពថវិកាមួយមានសមិទ្ធកម្មល្អនៅឡើយ គឺទាមទារឱ្យមានការវិភាគ និងវាយតម្លៃប្រកបដោយឯករាជ្យ និងវិជ្ជាជីវៈ លើលក្ខខណ្ឌវិនិច្ឆ័យផ្សេងៗទៀត ដែលភារកិច្ចនេះ រាជរដ្ឋាភិបាលបានសម្រេចប្រគល់ជូនសវនកម្មផ្ទៃក្នុង។ ដូច្នេះ គោលការណ៍ណែនាំសវនកម្មសមិទ្ធកម្ម ដែលជាប្រធានបទគន្លឹះទី១មួយសម្រាប់សិក្ខាសាលាថ្ងៃនេះ នឹងជួយសវនករស្វែងយល់ថាតើសវនកម្មសមិទ្ធកម្មលើសកម្មភាព កម្មវិធី និងគម្រោងនានាត្រូវធ្វើដូចម្តេច។

៣. ក្នុងរយៈពេលចុងក្រោយនេះ ពាក់ព័ន្ធនឹងគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ រួមទាំងគម្រោងសាធារណៈដទៃទៀត រាជរដ្ឋាភិបាល ក៏ដូចជាការឆ្លើយតបទៅនឹងតម្រូវការរបស់ដៃគូអភិវឌ្ឍន៍ មានបំណងបង្កើនការយកចិត្តទុកដាក់បន្ថែមលើការត្រួតពិនិត្យ ឱ្យកាន់តែគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងហានិភ័យ និងផលបច្ច័យរបស់គម្រោងទាំងនេះ។ កន្លងមកគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ត្រូវបានត្រួតពិនិត្យតិចតួចនៅឡើយពីសំណាក់ស្ថាប័នត្រួតពិនិត្យរបស់រដ្ឋ ភាគច្រើនធ្វើដោយសវនកម្មពីផ្នែកឯកជន។ ម្យ៉ាងទៀត ភាពចាំបាច់នៃការយកចិត្តទុកដាក់ជំរុញការងារសវនកម្មនេះ ក៏ជាការត្រៀមលក្ខណៈសម្បត្តិឆ្លើយតបទៅនឹងតម្រូវការត្រួតពិនិត្យគម្រោងសាធារណៈសហហិរញ្ញប្បទានរវាងរដ្ឋ និងវិស័យឯកជន ដែលត្រូវបាន

ប្រមើលឃើញថា នឹងអាចមានកំណើនខ្ពស់ក្នុងអនាគតដ៏ខ្លីខាងមុខ។ រាជរដ្ឋាភិបាលបានខិតខំកសាងលក្ខខណ្ឌអំណោយផលសម្រាប់គាំទ្រ និងទាក់ទាញវិស័យឯកជនមកបង្កើតគម្រោងប្រភេទនេះ ទាំងផ្នែករឹង និងទន់នៅគ្រប់ផ្នែកពាក់ព័ន្ធ ហើយបច្ចុប្បន្ន ការរៀបចំច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន ក៏កំពុងស្ថិតក្នុងដំណាក់កាលបញ្ចប់ផងដែរ។ ដូច្នេះ ដើម្បីបំពេញតម្រូវការបានទាន់ពេលវេលា និងសមស្របទៅនឹងទំហំនៃការត្រួតពិនិត្យលើគម្រោងទាំងនេះ សវនករផ្ទៃក្នុងក៏មានបុព្វសិទ្ធិពិសេសនាថ្ងៃនេះទទួលបាននូវបទឧទ្ទេសក្រោមប្រធានបទ “គោលការណ៍ណែនាំសវនកម្មលើគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍” ផងដែរ។

៤. បើយើងក្រឡេកមើលខាងបច្ចេកវិទ្យាព័ត៌មានវិញ ឃើញថា បច្ចេកវិទ្យាព័ត៌មានបានដើរតួជាស្នូលនៃស្នូលរបស់បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដែលជាគ្រឹះនៃយុគ្គសម័យរីកចម្រើនថ្មីរបស់ពិភពលោក នាពេលបច្ចុប្បន្ន។ វាក្យស័ព្ទថ្មី និងប្លែកៗគួរជក់ចិត្ត ដែលជាសញ្ញាណនៃការរីកចម្រើននេះ ត្រូវបានបង្ហាញខ្លួននិងដណ្តើមប្រជាប្រិយភាពកាន់តែខ្លាំងក្លាឡើង ដូចជាៈ សេដ្ឋកិច្ចឌីជីថល (Digital Economy) រដ្ឋាភិបាលអេឡិចត្រូនិក (Electronic Government) បញ្ញាសិប្បនិមិត្ត (Artificial Intelegence) ថ្នាលថ្មី (New Platform) ទិន្នន័យយក្ស (Big Data) ក្លោដ៍ (Cloud) រ៉ូបូទិក (Robotics)..។ល។ នៅក្នុងបរិការណ៍នេះ ក្នុងបំណងអភិវឌ្ឍន៍រាជរដ្ឋាភិបាលឌីជីថលពេញលេញ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការបន្តពង្រីក និងពង្រឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន នៅគ្រប់ក្រសួង ស្ថាប័ន គ្រប់ផ្នែក និងគ្រប់កម្រិតការងារ ពិសេសក្នុងកិច្ចការកែទម្រង់របស់ខ្លួន។ នៅដើមឆ្នាំ២០១៩ រាជរដ្ឋាភិបាល (ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ) បានបង្កើតនូវក្រុមការងារ ដើម្បីកំណត់ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថលរយៈពេលវែង។ ក្របខណ្ឌនេះ ផ្តោតលើៈ

- អភិវឌ្ឍន៍ និងដំណើរការនូវរដ្ឋាភិបាលឌីជីថលពេញលេញ (ប្រសិទ្ធភាពសេវាសាធារណៈ)
- ជំរុញវិនិយោគហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង (កាប្លិអុបទិក, កាប្លិក្រោមសមុទ្រ, មជ្ឈមណ្ឌលទិន្នន័យ)
- ស្រូបជាអតិបរមាពីអត្ថប្រយោជន៍នៃឌីជីថលូបនីយកម្ម (អក្ខរភាពឌីជីថល, STEAM, R&D, ...)
- រៀបចំនិងដាក់ដំណើរការនូវគោលនយោបាយ បទដ្ឋាន និងស្តង់ដា ពិសេសលើបញ្ហាសន្តិសុខ
- លើកកំពស់ការអភិវឌ្ឍន៍ប្រព័ន្ធអេកូ (បង្កើតៈ មូលនិធិអភិវឌ្ឍន៍ជំនាញ, មជ្ឈមណ្ឌល Startup តេជោ, មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព, ធនាគារ SME)។

ជាសក្ខីភាព ថ្មីៗនេះរាជរដ្ឋាភិបាលក៏បានសម្រេចដាក់ឱ្យដំណើរការនូវ “ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន” ដែលជួយធុរជនទទួលបាននូវការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ និងប្រកាសជូនព័ត៌មានស្តីពីការបើកក្រុមហ៊ុន ទៅក្រសួងមុខងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងពេលតែមួយ និងមានរយៈពេលត្រឹម៨ ថ្ងៃ ដោយចំណាយតិចជាងមុនពាក់កណ្តាល។ ជាមួយគ្នានេះ ប្រព័ន្ធចុះបញ្ជីគម្រោង

វិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏បានដាក់ឱ្យដំណើរការដោយផ្សារភ្ជាប់ជាមួយប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ហើយអ្វីដែលគួរចាប់អារម្មណ៍បន្ថែមនៅក្នុងវឌ្ឍនភាពនេះ គឺការកសាងថ្នាលផ្លាស់ប្តូរទិន្នន័យ ( Cambodia Data Exchange, CamDX) ដែលអនុញ្ញាតឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការចុះបញ្ជីអាជីកម្មអាចផ្លាស់ប្តូរទិន្នន័យគ្នាបាន។ សេវាសាធារណៈផ្សេងៗទៀតនៅតាមក្រសួង ស្ថាប័នរដ្ឋ ក៏នឹងត្រូវរៀបចំតាមគន្លងរបៀបគ្នានេះដែរនាពេលខាងមុខ។

ដោយឡែក នៅក្នុងក្របខណ្ឌនៃកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមិននិយាយដល់ប្រព័ន្ធទាំងឡាយបាន/កំពុងបង្កើតនៅតាមអង្គភាពក្រោមឱវាទ កសហវ គឺចាប់តាំងពីដំណាក់កាលទី២ "**ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ**" ប្រព័ន្ធ FMIS ត្រូវបានបង្កើត និងកំពុងបន្តពង្រីកពង្រឹងតួនាទីរបស់ខ្លួន។ ក្រោយពីការបញ្ចូលដំណើរការពាក់ព័ន្ធនឹងហិរញ្ញវត្ថុ និងគណនេយ្យទៅក្នុងប្រព័ន្ធ បច្ចុប្បន្នដំណើរការទាំងនោះមួយចំនួន និងជាបន្តបន្ទាប់ត្រូវបានកាត់តម្រឹមនីតិវិធី ដើម្បីជណ្តើមប្រសិទ្ធភាពការងារកាន់តែខ្ពស់ ឧ. ចំណាយបៀវត្ស និងចំណាយផ្សេងៗដែលមានកម្រិតកំណត់ច្បាស់លាស់ និងមានវេទយិតភាពទាប។ ការកាត់តម្រឹមនេះបានក្លាយជាសកម្មភាពចំបង និងត្រូវបានកំណត់និងតម្រង់ទិស ដោយ"**ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ២០២០-២០២៥**" ។

ពិសោធន៍បច្ចុប្បន្ន ក៏បង្ហាញដែរថា ការជំរុញនិងតម្រូវការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន អាចមានប្រភពពីហេតុការណ៍ជាយថាហេតុ ដែលជាគ្រោះផងនិងកាលានុវត្តភាពផង។ តួយ៉ាង វត្តមាននិងឥទ្ធិពលនៃជម្ងឺកូវីដ-១៩ ដែលក្នុងខណៈកំពុងបង្កវិនាសកម្មលើសេដ្ឋកិច្ច សង្គម និងមនុស្ស បានក្លាយជាឃ្នាស់បង្កើនល្បឿននៃការអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ព្រមទាំងធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងលើទម្លាប់នៅក្នុងជីវភាពរស់នៅ និងការងារប្រចាំថ្ងៃ សម្រាប់ការគិត ការធ្វើ និងការប្រាស្រ័យទាក់ទងរវាងគ្នា ដែលជាការបើកទំព័រប្រវត្តិសាស្ត្រនៃ "ទម្លាប់ធម្មតាថ្មី New Normal Order"។ គ្រាន់តែគោលការណ៍ "រក្សាចម្ងាយសង្គម" តែមួយមុខ បានបង្ខំឱ្យវិស័យបច្ចេកវិទ្យាព័ត៌មានត្រូវតម្រែតម្រង់ខ្លួនជាថ្មី (Reshape) និងធ្វើពិពិធកម្មមែកធាងចាំបាច់មួយចំនួន ជាមួយល្បឿនលឿនជាងច្រើនដងបើធៀបនឹងជីវភាពតាម "ទម្លាប់ធម្មតាចាស់ Old Normal Order" ឧ. កម្មវិធីនានាទាក់ទងនឹងសកម្មភាពអនឡាញ។

ដូច្នេះ តម្រូវការបច្ចេកវិទ្យាព័ត៌មានពិតជាមានទំហំធំ និងឈានដល់ដំណាក់កាលពុំអាចព្យាករណ៍បានឡើយ តែទោះជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបង្កើតថ្មី កាន់តែមានសមត្ថភាពខ្លាំង មានប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់ជាងមុន ក៏ហានិភ័យនិងភាពបរាជ័យបច្ចេកវិទ្យាព័ត៌មាននៅតែពុំអាចផុតរលត់បានឡើយ។ ប្រការនេះ ទាមទារឱ្យមានការពង្រឹងការធ្វើសវនកម្មជាមួយវិធីសាស្ត្រថ្មីៗ ដែលទោះជាយ៉ាងណា គោលបំណងសវនកម្មរួមនៅតែពុំផ្លាស់ប្តូរ គឺប្រព័ន្ធនីមួយៗត្រូវតែមានគោលបំណងសមស្រប ត្រូវបានតាក់តែង (Design) ដោយបំពាក់ប្រព័ន្ធត្រួតពិនិត្យគ្រប់គ្រាន់ រឹងមាំ និងមានប្រតិបត្តិការ (Operation) ប្រកបដោយប្រសិទ្ធភាព ហើយប្រព័ន្ធទាំងមូលត្រូវងាយស្រួលប្រើប្រាស់ និងដំណើរការបានទៅតាមការរំពឹងទុក។ គោល

ការណ៍ណែនាំសវនកម្មបច្ចេកវិទ្យាព័ត៌មាន ដែលជាប្រធានបទមួយក្នុងចំណោមប្រធានបទទាំងបី នឹងជួយសវនកររអេះអាងលើគោលបំណងនេះ។

**អង្គសិក្ខាសាលា ជាទីមេត្រី** !

**៥-** ខ្ញុំសូមអនុញ្ញាតទាញអារម្មណ៍បន្តិចថា នៅក្នុងការអនុវត្តមុខងារសវនកម្មផ្ទៃក្នុងកន្លងមក យើងពិតជាបានជួបប្រទះការលំបាកតូចធំជាច្រើន តែយើងបានជម្នះ និងធ្វើឱ្យមុខងារនេះមានការរីកចម្រើនធំធាត់ដូចសព្វថ្ងៃ។ ប៉ុន្តែ ទន្ទឹមនឹងការចាប់ផ្តើម/ពង្រឹងការអនុវត្តសវនកម្មទាំងបី គឺសវនកម្មសមិទ្ធកម្ម សវនកម្មលើគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន ក្រោយពេលបញ្ចប់សិក្ខាសាលានេះ សវនករអាចជួបប្រទះការលំបាក និងភាពស្មុកស្មាញជាងមុនមួយចំនួនទៀត។ ការលំបាកថ្មីមិនគ្រាន់តែស្ថិតត្រង់ថា សវនករត្រូវខិតខំហ្វឹកហាត់ និងអនុវត្តនូវវិធីសាស្ត្រសវនកម្មថ្មី ឬកម្មវត្ថុសវនកម្មជាកម្មវត្ថុដែលមានលក្ខណៈបច្ចេកទេសខ្លាំងជាងមុននោះទេ តែសវនករអាចនឹងកត់សម្គាល់ឃើញថា ភាពរួបីនៃទីសវនកម្មត្រូវបានកាត់បន្ថយ (ផ្នែកបច្ចេកវិទ្យាព័ត៌មាន ឧ. Audit log) និងលក្ខណៈវិនិច្ឆ័យសវនកម្មក៏កាន់តែបាត់បង់ភាពជាក់លាក់ និងភាពស្តង់ដា គឺភាគច្រើនត្រូវពឹងផ្អែកលើការវិភាគ និងវិនិច្ឆ័យផ្ទាល់របស់សវនករ ហើយក៏ពុំអាចប្រើប្រាស់បានទូលាយនៅទីសវនកម្មផ្សេងទៀត (ផ្នែកសមិទ្ធកម្ម) ដូចលក្ខណៈវិនិច្ឆ័យនៅក្នុងសវនកម្មបែបអនុលោមភាពឬហិរញ្ញវត្ថុនោះឡើយ។ ប្រការនេះ ពិតជាធ្វើឱ្យសវនករមានការលំបាកបន្តិចក្នុងការសិក្សាស្វែងយល់ វិភាគនិងកំណត់ហានិភ័យ ធ្វើតេស្តនិងសន្និដ្ឋាន ព្រមទាំងការផ្តល់អនុសាសន៍សវនកម្ម។ ដូច្នេះ សូមសិក្ខាកាមត្រូវផ្ចិតផ្ចង់ត្រងត្រាប់បទឧទ្ទេសឱ្យបានហ្មត់ចត់ ជម្រះចម្ងល់ឱ្យបានច្រើនតាមតែអាចធ្វើបាន។ លើសពីនេះ ការយល់ដឹងផ្នែកទស្សនៈវិជ្ជា និងចំណេះដឹងទូទៅរបស់សវនករ ដោយមិនទាន់និយាយដល់ជំនាញនិងការយល់ដឹងអំពីការអភិវឌ្ឍន៍ក្រសួង ស្ថាប័នរបស់ខ្លួន គឺត្រូវពង្រឹងពង្រីកឱ្យបានជាប់ជាប្រចាំ ដើម្បីធានាឱ្យគុណភាពនៃការវិភាគ ការវិនិច្ឆ័យ ការសន្និដ្ឋាន និងការផ្តល់អនុសាសន៍ មានលក្ខណៈគ្រប់ជ្រុងជ្រោយ មានប្រតិតុល្យភាព ប្រកបដោយគុណតម្លៃ អាចទទួលយកនិងអនុវត្តបានដោយសវនដ្ឋាន។ ឆ្លៀតឱកាសនេះ ខ្ញុំសូមអនុញ្ញាតក្រើនរម្លឹកដល់សវនកម្មផ្ទៃក្នុង ដែលពុំទាន់រៀបចំសមស្របនូវសមត្ថភាពសវនកម្មបច្ចេកវិទ្យាព័ត៌មាន គឺត្រូវរួសរាន់រៀបចំដោយមិនអួសបន្លាយ ព្រោះកង់ប្រវត្តិសាស្ត្រនៃកំណែទម្រង់មិនអនុញ្ញាតឱ្យគេចកែឬរម្លងសវនកម្មនេះបានឡើយ។

**មិត្តសវនករជាទីរាប់អាន**!

**៦.** ទោះជាយើងបានប្រមើលឃើញនូវបញ្ហាប្រឈម ដែលផ្សារភ្ជាប់ជាមួយការចាប់ផ្តើម/ពង្រឹងការ

អនុវត្តសវនកម្មទាំងបីដ៏គួរឱ្យព្រួយបារម្ភក៏ដោយ ក៏ជាមួយការគាំទ្ររបស់រាជរដ្ឋាភិបាល ពិសេសរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងការបន្តជួយជ្រោមជ្រែងផ្នែកបច្ចេកទេស ពីសំណាក់ដៃគូរអភិវឌ្ឍន៍នានា ពិសេសធនាគារអភិវឌ្ឍន៍អាស៊ី យើងពិតជាមានជំនឿដោយមោទនភាពថា យើងអាចបន្តជម្នះបញ្ហាប្រឈមទាំងនោះម្តងមួយៗ ហើយនៅតែអាចផ្តល់សេវាសវនកម្ម ពិសេសសវនកម្មសមិទ្ធកម្ម គម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងបច្ចេកវិទ្យាព័ត៌មានប្រកបដោយប្រសិទ្ធភាព និងជាទីពេញចិត្តនៃថ្នាក់ដឹកនាំក្រសួងស្ថាប័នរបស់យើង។ អាស្រ័យហេតុនេះ តាងនាមឱ្យសវនករផ្ទៃក្នុងទាំងអស់ ខ្ញុំសូមសំដែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាល ចំពោះឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃ កសហវ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ដែលតែងតែផ្តល់ការណែនាំ និងគាំទ្រយ៉ាងសកម្ម ធ្វើឱ្យមុខងារសវនកម្មផ្ទៃក្នុងបានរីកធំធាត់ និងអាចបំពេញតួនាទីភារកិច្ចរបស់ខ្លួនដោយឯករាជ្យ និងទទួលបានលទ្ធផលល្អ។ ខ្ញុំក៏សូមកោតសរសើរព្រមទាំងវាយតម្លៃខ្ពស់ចំពោះអង្គភាពសវនកម្មផ្ទៃក្នុងទាំងអស់ ចំពោះការខិតខំបំពេញតួនាទីរបស់ខ្លួន និងសូមលើកទឹកចិត្តឱ្យបន្តពុះពារជម្នះរាល់ឧបសគ្គនានា ដើម្បីរួមចំណែកផ្តល់សេវាសវនកម្មឱ្យបានជាឧត្តមប្រយោជន៍ជូនស្ថាប័នរៀងៗខ្លួនថែមទៀត។ ទន្ទឹមនឹងនេះ ខ្ញុំសូមអរគុណដល់អង្គភាពពាក់ព័ន្ធនៃ កសហវ ដូចជាវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាននៃគណកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលតែងតែផ្តល់កិច្ចសហការជិតស្និទ្ធ គាំទ្រដល់គ្រប់វគ្គបណ្តុះបណ្តាលសវនកម្មឱ្យ សម្រេចបានជោគជ័យជាបន្តបន្ទាប់។ ចុងក្រោយមែន តែមិនអាចរម្លងបាន គឺថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានពុះពារបំពេញការងារមួយជាបី ណាការងារជំនាញប្រចាំថ្ងៃ ណាការងារគាំទ្រដល់សវនកម្មផ្ទៃក្នុងតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ ណាការងាររៀបចំបទដ្ឋានគតិយុត្តនិងរៀបចំវគ្គបណ្តុះបណ្តាល ដូចជាសិក្ខាសាលាអនឡាញក្នុងថ្ងៃនេះជាដើម ត្រូវតែទទួលបាននូវការអរគុណ ដឹងគុណ និងមូលវិចារណ៍ល្អដ៏វិសេសចំពោះមុខនាពេលនេះ។

**៧-** ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរ **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា** សូមមានសុខភាពល្អបរិបូណ៌ និងសមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ ពិសេសសូមឱ្យចាកចៀសផុតពីជម្ងឺកូវីត-១៩ នេះគ្រប់ៗគ្នា និងគ្រប់ក្រុមគ្រួសារ។

ខ្ញុំសូមប្រកាសបើកអង្គសិក្ខាសាលាពីពេលនេះតទៅ !